**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jun-2011, 11:38
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់របស់ សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យមានការបញ្ជាក់បំភ្លឺ ព្រមទាំងសុំពន្យារពេលវេលា ក្នុងការឆ្លើយតបចំពោះសេចក្តីណែនាំ លេខ E93 របស់អង្គជំនុំជម្រះសាលាដំបូង**

---

ដាក់ដោយ៖

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

**ផ្ញើជូន៖**

ឡៅ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

គង់ ពិសី

យុង ផានិត

សំ សុគង់

វ៉ែន ពៅ

ទី ស្រីនណា

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Silke STUDZINSKY
Philippine SUTZ

**<u>ការិយាល័យសហព្រះរាជអាជ្ញា៖</u>**

ជា លាង

Andrew T. CAYLEY

យ៉ែត ចរិយា

William SMITH

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅសៀង

Diana ELLIS

ស សុវាន

Jacques VERGES

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញ "ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" (E9) ដែលនៅក្នុងដីកានេះ បានស្នើឲ្យភាគី ដាក់ឯកសារនានា ដែលក្នុងចំណោមឯកសារទាំងនោះ ត្រូវមាន "បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី ដែលអ្នកទាំងនោះមិនបានស្នើសុំនូវវិធានការការពារ" "បញ្ជីឈ្មោះសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីថ្មី ដែលស្នើសុំវិធានការការពារ" ព្រមទាំង "ព័ត៌មានដែលតម្រូវឲ្យមាន ទាក់ទិនទៅនឹងសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ"។

២. នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញា ដោយគោរពតាមដីកានេះ បានដាក់នូវ "សេចក្ដីសង្ខេបអំពីអ្នកជំនាញ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០ ដោយរួមទាំងឧបសម្ព័ន្ធសម្ងាត់ ១, ២, ៣, ៣ក, ៤ និង ៥" (E9/13)។

៣. នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់ "បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី របស់ សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់ ១, ២ក, ២ខ, ២គ, ៣ក, ៣ខ និង ៤"(E9/4/3)។ នៅក្នុងថ្ងៃដដែលនេះ ក្រុមមេធាវីការពារក្ដីទាំងបួនក្រុម បានដាក់បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួនផងដែរ[១]។

៤. នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញនូវឯកសារមួយដែលមានចំណងជើងថា "កាលបរិច្ឆេទសវនាការបឋម"(E86)។

៥. នៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញ "សេចក្ដីណែនាំនៅមុនពេលសវនាការបឋម ពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ"(E93)។

---

[១] ក្រុមមេធាវីកាពារក្ដី នួនជា មានលេខឯកសារ E9/10, ក្រុមមេធាវីកាពារក្ដី អៀង ធីរិទ្ធ មានលេខឯកសារ E9/4/5 ក្រុមមេធាវីកាពារក្ដី អៀង សារី មានលេខឯកសារ E9/4/2 និង ក្រុមមេធាវីកាពារក្ដី ខៀវ សំផន មានលេខឯកសារ E9/4/4 ។

សំណើបន្ទាន់របស់ សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឲ្យមានការបញ្ជាក់បំភ្លឺ ព្រមទាំងសុំពន្យារពេលវេលា ក្នុងការឆ្លើយតបចំពោះសេចក្ដីណែនាំ លេខ E93 របស់អង្គជំនុំជម្រះសាលាដំបូង

៦. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញ "របៀបវារៈសម្រាប់សវនាការបឋម" (E86/1)។

II. **សំណើសុំការបញ្ជាក់បំភ្លឺ ជាបន្ទាន់**

៧. សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមលើកឡើងដោយក្តីគោរពថា អង្គជំនុំជម្រះសាលាដំបូងមិនបានចេញ សេចក្តីណែនាំណាមួយ នៅមុនពេលសវនាការបឋម ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំឲ្យកោះហៅនោះទេ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបាននិយាយយោងតែទៅលើសាក្សី និងអ្នកជំនាញតែប៉ុណ្ណោះ[២]។

៨. នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវឯកសារមួយ ដែលមានចំណងជើងថា "កាលបរិច្ឆេទសវនាការបឋម"(E86) ដែលឯកសារនេះបានជូនដំណឹងដល់ភាគីនានា អំពីបញ្ហាដែលត្រូវធ្វើការពិចារណានៅក្នុង សវនាការបឋម។ បញ្ហាទាំងនោះរួមមាន "បញ្ហាបញ្ជីឈ្មោះ**សាក្សី** និងអ្នកជំនាញ ដែលភាគីបានដាក់អនុលោមតាមវិធានផ្ទៃក្នុង"។

៩. នៅថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញ "សេចក្តីណែនាំនៅមុនពេលសវនាការបឋម ពាក់ព័ន្ធនឹង**សាក្សី**ដែលភាគីស្នើសុំកោះហៅ"(E93) ដែលសេចក្តីណែនាំនេះបានជូនដំណឹងដល់ភាគីនានាថា នៅក្នុងសវនាការបឋម អង្គជំនុំជម្រះនឹងកម្រិតការពិភាក្សាអំពី "**សាក្សី និងអ្នកជំនាញ**" ដែលភាគីបានស្នើសុំកោះហៅ។ បន្ទាប់ពីបាន "វិភាគលើបញ្ជីឈ្មោះ**សាក្សី**" អង្គជំនុំជម្រះសាលាដំបូងស្នើសុំឲ្យភាគីដាក់ជូនអង្គជំនុំជម្រះត្រឹមថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ នូវបញ្ជីសង្ខេបរបស់ **សាក្សី** ដែលពាក់ព័ន្ធទៅនឹងចំណុចទាំង៤ ដែលបានរៀបរាប់ក្នុងសេចក្តីណែនាំ ដូចបានបង្ហាញពីខាងលើ ហើយសូមបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងនឹងពិភាក្សាតែចំពោះ "**សាក្សី និងអ្នកជំនាញ**" ដែលពាក់ព័ន្ធទាំងនេះ តែប៉ុណ្ណោះ។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "បន្ទាប់ពីសវនាការបឋម និងក្រោយការស្តាប់សេចក្តីសន្និដ្ឋានរបស់ភាគី អង្គជំនុំជម្រះនឹងប្រកាសបញ្ជីឈ្មោះ**សាក្សី**បឋមសម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះ។ (**សាក្សី**ពាក់ព័ន្ធផ្សេងៗអាចត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះសាក្សីបម្រុង

[២] កាលបរិច្ឆេទសវនាការបឋម E86,សេចក្តីណែនាំនៅមុនពេលសវនាការបឋម E93, របៀបវារៈសម្រាប់សវនាការបឋម E86/1។

សម្រាប់ឲ្យអង្គជំនុំជម្រះកោះហៅក្នុងករណី**សាក្សី**ដែលមានឈ្មោះនៅក្នុងបញ្ជីបឋមពុំអាចចូលខ្លួនមកផ្តល់សក្ខីកម្មបាន)"។

១០. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញ "របៀបវារៈសម្រាប់សវនាការបឋម" (E86/1) ដែលរបៀបវារៈនេះបានបែងចែកពេលវេលា ដូចតទៅ៖ "*ចំណុចទី១* ប្រកាសអំពីបញ្ជីឈ្មោះ**សាក្សី**បណ្តោះអាសន្ន សម្រាប់ដំណាក់កាលដំបូង នៃការជំនុំជម្រះលើអង្គសេចក្តី (...) *ចំណុចទី៨* ការទាញហេតុផលដោយផ្ទាល់មាត់ទាក់ទងនឹងការជំទាស់នានា ប្រសិនបើមាន ទាក់ទិននឹងបញ្ជីឈ្មោះ**សាក្សី**ដែលបានស្នើឡើងកន្លងមក សម្រាប់ការចាប់ផ្តើមសវនាការលើអង្គសេចក្តី"។

១១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ផ្នែកសហមេធាវីនាំមុខ បានស្នើសុំការបញ្ជាក់បំភ្លឺតាមរយៈអ៊ីម៉ែល ដោយផ្ញើជូនទៅលោកស្រី Susan Lamb ដែលជាមន្ត្រីច្បាប់ជាន់ខ្ពស់ប្រចាំ អង្គជំនុំជម្រះសាលាដំបូង ថា "*តើអង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្តីណែនាំបន្ថែមទាក់ទងជាពិសេសចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើឲ្យកោះហៅដោយភាគីនានា អនុលោមទៅតាមដីកា E9 របស់អង្គជំនុំជម្រះសាលាដំបូង ដែរឬទេ ព្រោះថាទាំងក្នុង សេចក្តីណែនាំនៅមុនពេលសវនាការបឋម E93 និងរបៀបវារៈសម្រាប់សវនាការបឋម E86/1 ចំណុច ១ និងចំណុច ៨ ដែលបានចេញនាពេលបន្ទាប់មកសុទ្ធតែមាននិយាយរួមបញ្ចូលនូវដើមបណ្តឹងរដ្ឋប្បវេណី (ជាឧទាហរណ៍ ក្នុងឧបសម្ព័ន្ធ ២ក និង ២ខ នៃ បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់ សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ៨០*"។ ក្នុងចម្លើយតបដែលបានទទួលក្នុងថ្ងៃដដែលនេះ លោកស្រី Susan បានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងនឹងមិន "*ចេញសេចក្តីណែនាំបន្ថែម ទាក់ទងទៅនឹងផ្នែកនេះទេ។ លោក/លោកស្រីអាចអានដីកាទាំងនេះ ដែលដីកាទាំងនេះតម្រូវឲ្យភាគីនានាផ្តល់នូវបញ្ជីបន្ថែមសម្រាប់បុគ្គលទាំងឡាយណាដែលភាគីបានស្នើសុំឲ្យផ្តល់សក្ខីកម្ម នៅក្នុងដំណាក់កាលដំបូងនៃការជំនុំជម្រះ (រួមបញ្ចូលទាំងដើមបណ្តឹងរដ្ឋប្បវេណីផង ប្រសិនបើពួកគាត់មានការពាក់ព័ន្ធ) (...)*"។

១២. ជាការឆ្លើយតបទៅនឹងអ៊ីម៉ែលនេះ សហមេធាវីនាំមុខ បានស្នើសុំការបញ្ជាក់បំភ្លឺបន្ថែមដូចតទៅ៖ "*១. តើសេចក្តីណែនាំ E93 និយាយយោងផងដែរដល់ដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ? ប្រសិនបើនិយាយយោងដល់ដើមបណ្តឹងរដ្ឋប្បវេណី តើអង្គជំនុំជម្រះសាលាដំបូងចង់ស្នើសុំអ្វីសម្រាប់កាល*

*បរិច្ឆេទថ្ងៃទី ២០ ខែ មិថុនា ទាក់ទិនដល់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ឧបសម្ព័ន្ធ ២ក និង ២ខ? ២. ដើម្បីសម្រួលដល់ការរៀបចំសម្រាប់សវនាការ តើភាគីនានាត្រូវផ្តល់ព័ត៌មានពីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ តាមលំដាប់លំដោយនៃភាពពាក់ព័ន្ធ និងតម្លៃជាភស្តុតាង ទាក់ទិនទៅនឹងចំណុចទាំង៤ ដែល អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងដែរឬទេ?'* លោកស្រី Susan បានផ្តល់ចម្លើយតបដូចតទៅ "*១. ចាស ពិតជានិយាយយោងដល់ដើមបណ្តឹងរដ្ឋប្បវេណីមែន ហើយសហមេធាវីនាំមុខ (ដូចជាភាគីនានាដែរ) អាចដាក់ជូននូវបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធ ប្រសិនបើមាន។ ប្រសិនបើគ្មានសក្ខីកម្មរបស់ ដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ទាក់ទងនឹងចំណុចទាំង៤ ដែលបាននិយាយពីខាងដើមមកទេ គឺមិនចាំបាច់ត្រូវដាក់បញ្ជីមកនោះទេ។ ២. ក្នុងករណីដែលត្រូវដាក់បញ្ជីឈ្មោះ បញ្ជីនោះត្រូវដាក់តាមលំដាប់លំដោយ នៃភាពពាក់ព័ន្ធ/តម្លៃជាភស្តុតាង (ដោយមានការពណ៌នារៀបរាប់យ៉ាងតិចតួចបំផុត ក្នុងករណីដែលចាំបាច់)*"។

១៣. សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណីពិចារណាថា សេចក្តីណែនាំថ្ងៃទី ៣ ខែ មិថុនា ព្រមទាំងរបៀបវារៈសម្រាប់សវនាការបឋម បានបង្កើតនូវភាពមិនច្បាស់លាស់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ភាពមិនច្បាស់លាស់គឺត្រង់ថា តើអាចមានការចេញសេចក្តីណែនាំបន្ថែមទៀតឬទេ ព្រោះសេចក្តីណែនាំបាននិយាយយោងតែទៅលើ **សាក្សី និងអ្នកជំនាញ** ឬមួយក៏អង្គជំនុំជម្រះសាលាដំបូង មានចេតនាដាក់បញ្ចូលដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងក្រុម "សាក្សី និងអ្នកជំនាញ"។

១៤. ទោះជាយ៉ាងណាក្តី ដោយសារមានការរំពឹងទុកថា អង្គជំនុំជម្រះសាលាដំបូងបានយល់ច្បាស់ពីការប្រើប្រាស់ពាក្យពេចន៍ច្បាប់នោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចរំពឹងដោយសមហេតុផលថា សេចក្តីណែនាំក៏សំដៅដល់ដើមបណ្តឹងរដ្ឋប្បវេណីផងដោយមិនបាននិយាយឲ្យចំៗនោះទេ។ អាស្រ័យហេតុនេះ សេចក្តីណែនាំនេះបានលើកឡើងនូវកង្វល់នានាដែលថា អង្គជំនុំជម្រះសាលាដំបូងមិនបានពិនិត្យទៅលើបញ្ជីនានា ដែលបានដាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី និងភាពពាក់ព័ន្ធនៃបញ្ជីទាំងនោះចំពោះភស្តុតាងផ្ទាល់ទេ ដោយសារមានការអះអាងថា អង្គជំនុំជម្រះសាលាដំបូងត្រឹមតែ"បានវិភាគទៅលើបញ្ជី**សាក្សី**"ប៉ុណ្ណោះ។

១៥. អាស្រ័យហេតុនេះ រហូតទាល់តែសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានទទួលដំណឹងពីអង្គជំនុំជម្រះសាលាដំបូងលើបញ្ហានេះ បើមិនដូច្នោះទេ ការត្រៀមរៀបចំបញ្ជីសាក្សី និងអ្នកជំនាញអនុលោមសេចក្តីណែនាំលេខ E93 របស់អង្គជំនុំជម្រះសាលាដំបូងក៏នៅមានកម្រិតដែរ។

១៦. អង្គជំនុំជម្រះសាលាដំបូងគួរបញ្ជាក់ពីការបកស្រាយ ដែលបានលើកឡើងនៅក្នុងសារអេឡិចត្រូនិចរបស់ Susan Lamb នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ នូវការពន្យារកាលបរិច្ឆេទចុងក្រោយពីមុននៅត្រឹមថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ នោះ (ដែលជាថ្ងៃឈប់សម្រាកដែរ) ត្រូវបានស្នើសុំដើម្បីអនុញ្ញាតឲ្យសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ជូននូវបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ដែលត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្មនៅក្នុងចំណុចដំបូងនៃសវនាការ។

## III. ដើមបណ្តឹងរដ្ឋប្បវេណីខុសគ្នាស្រឡះពីសាក្សី

១៧. បើតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់"[៣] នៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក។

១៨. ការចូលរួមនៅក្នុងបរិបទរបស់ អ.វ.ត.ក មានន័យថា ជាការអនុវត្តសិទ្ធិរបស់ខ្លួន *ក្នុងចំណោមនោះ* ដូចជា (១).ការដាក់បញ្ជីសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារនានារបស់ខ្លួន (២).ការសាកសួរសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទ (៣).ការស្នើសុំបំពេញកិច្ចស៊ើបសួរ (៤).ការផ្តល់សក្ខីកម្មតាមផ្លូវច្បាប់ (៥).ការបង្ហាញភស្តុតាងនៅចំពោះមុខ អ.ជ.ស.ដ និង (៦).ការផ្តល់ចម្លើយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរចំពោះភស្តុតាងដាក់បន្ទុក។

---

[៣] វិធាន២៣(១) នៃវិធានផ្ទៃក្នុងបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិ "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់"។

១៩. បន្ថែមទៅលើសិទ្ធិរបស់ខ្លួនក្នុងការចូលរួមយ៉ាងសកម្មទៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចត្រូវបានកោះហៅដោយភាគីដទៃទៀត ដើម្បីផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការ ដែរ។ វិធាន៩១(១) នៃវិធានផ្ទៃក្នុងចែងថា "អង្គជំនុំជម្រះសាលាដំបូងត្រូវស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ទៅតាមលំដាប់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍"។

២០. វិធានផ្ទៃក្នុងបានបែងចែកដាច់ស្រឡះពីគ្នារវាង ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ[៤]។ ភាពខុសគ្នាជាមូលដ្ឋានគឺផ្អែកទៅលើឋានៈតាមផ្លូវច្បាប់ ដែលបានផ្តល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌថា៖ ដើមបណ្តឹងរដ្ឋប្បវេណីមិនមែន និង មិនអាចត្រូវបានចាត់ទុកថាជាសាក្សីទេ[៥]។

២១. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ដើមបណ្តឹងរដ្ឋប្បវេណីសូមបញ្ជាក់ឡើងវិញនូវសារៈសំខាន់នៃការរក្សាភាពដាច់ស្រឡះពីគ្នានេះ ដើម្បីរក្សានូវឋានៈតាមផ្លូវច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។

## IV. ដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកផ្តល់សក្ខីកម្ម

២២. ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ១៨៣ (មួយរយប៉ែតសិបបី) នាក់ ដែលត្រូវបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤៦ (មួយរយសែសិបប្រាំមួយ) នាក់ ត្រូវបានស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

---

[៤] វិធាន៩១(១)។ សូមមើលផងដែរ៖ ដើមបណ្តឹងរដ្ឋប្បវេណី និង សាក្សីមានវិធានពីរដាក់ស្រឡះពីគ្នាដើម្បីអនុវត្ត សូមមើលជាឧទាហរណ៍នូវវិធាន១២*ស្ទួនពីរ* វិធាន២៣ វិធាន២៣*ស្ទួន* វិធាន២៣*ស្ទួនបី* វិធាន២៣*ស្ទួនបួន* វិធាន៥៩ វិធាន៩១ វិធាន១០០ វិធាន១០១ ដែលចែងជាពិសេសអំពីដើមបណ្តឹងរដ្ឋប្បវេណី ចំណែកវិធាន២៤ វិធាន២៥ វិធាន២៦ វិធាន២៧ វិធាន២៨ វិធាន៦០ វិធាន៨៤ ចែងជាពិសេសតែចំពោះសាក្សីដែលត្រូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៅក្នុងដំណាក់កាលផ្សេងៗនៃនីតិវិធីតែប៉ុណ្ណោះ។

[៥] ភាពខុសគ្នាស្រឡះនេះក៏ត្រូវបានគាំទ្រផងដែរដោយអង្គហេតុដែលថា ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះដោយពុំចាំបាច់ធ្វើសម្បថទេ សូមមើលវិធាន២៤(២) នៃវិធានផ្ទៃក្នុង សូមមើល Observation des parties civiles sur la motion présentée par Ieng Sary aux fins de prestation de serment par les parties civiles préalablement à leur témoignage, 17 mars 2010, Doc n° **E57/1**។ សូមមើលផងដែរបញ្ញត្តិដែលមានចែងក្នុងមាត្រា៣១២ នៃ CPC ដែលចែងថា "ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចត្រូវគេស្តាប់ចម្លើយក្នុងឋានៈជាសាក្សីបានទេ"។

និង មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែឯង។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនក្នុងចំណោម នេះបានផ្ដល់ភស្តុតាងពាក់ព័ន្ធនឹងចំណុចដំបូងៗនៃសវនាការ។

២៣. ជាងនេះទៅទៀត ហើយដូចដែលធ្លាប់លើកឡើងទៅក្នុងសារណាមុនៗរបស់ខ្លួនរួចមកហើយគឺថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមរក្សាសិទ្ធិរបស់ខ្លួន ក្នុងការកែប្រែបញ្ជីនោះ នៅពេលបានទទួលសាលដីការបស់អង្គបុរេជំនុំជម្រះ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រម ស៊ើបអង្កេត ទាក់ទិននឹងការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

២៤. វាជាប្រការសំខាន់បំផុតដែលថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និង មេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលបាននូវសេចក្ដីណែនាំបន្ទាន់នានា ទាក់ទិននឹងការធ្វើសក្ខី កម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងដំណាក់កាលដំបូងនៃសវនាការលើអង្គសេចក្ដី ទាក់ទិននឹង ចំណុចទាំងបួនដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង។

## V. "**ការកាត់បន្ថយ**" **បញ្ជីដើមបណ្ដឹងរដ្ឋប្បវេណី**

២៥. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាថា បញ្ជីដើមបណ្ដឹងរដ្ឋប្បវេណីចាំបាច់ត្រូវកាត់បន្ថយ នោះ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមទទូចថា មេធាវីតំណាងដើមបណ្ដឹង រដ្ឋប្បវេណីគួរតែរក្សាសិទ្ធិក្នុងការកាត់បន្ថយបញ្ជីទាំងនោះដោយខ្លួនឯង។ ទោះបីសហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងពីពេលវេលាតិចតួច ដែលអង្គជំនុំជម្រះសាលាដំបូងកំពុង ប្រឈម និង សូមកោតសរសើរចំពោះមូលហេតុនៃការអនុវត្តជាក់ស្ដែងសម្រាប់កាត់បន្ថយបញ្ជី ទាំងនេះក៏ដោយ ក៏សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើថា មេធាវីតំណាង ដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកដែលសក្តិសមជាងគេក្នុងការកាត់បន្ថយនូវបញ្ជីរបស់ខ្លួន ដើម្បីធានា ថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធបំផុត និងមានតម្លៃដែលគួរឲ្យជឿបានបំផុត ត្រូវបាន អង្គជំនុំជម្រះសាលាដំបូងកោះហៅឲ្យផ្ដល់សក្ខីកម្ម។

**សំណូមពរៈ**

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមស្នើថា៖

- អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ឲ្យច្បាស់ពីវិសាលភាពនៃ "សេចក្ដីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ" របស់ខ្លួន (E93) និង
- ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថាឯកសារ E93 បានរាប់បញ្ចូលនូវដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្នើសុំដែរនោះ សូមមេត្តាពន្យារពេលដើម្បីឲ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអាចដាក់បញ្ជីដែលបានកែប្រែ និង ការពន្យល់បន្ថែមទៀតផង។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើសុំនេះដោយក្ដីគោរព។

| កាលបរិច្ឆេទ | នាម និង គោត្តនាម | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ | **ពេជ អង្គ**<br>**សហមេធាវីនាំមុខ** | ភ្នំពេញ | |
| | Elisabeth SIMONNEAU FORT<br>**សហមេធាវីនាំមុខ** | ភ្នំពេញ | |